ផលិតចងក្រងដោយ NSW HEALTH DEPARTMENT

multicultural communication

Khmer-ខ្មែរ

30 June 1995
[HTS-669]

# របៀបរម្ងាប់មេរោគនៅនឹងឯបទឹកដោះ និងប្រដាប់ប្រដារប្រើប្រាស់ផ្សេងៗ

# How to Sterilize Bottles and Utensils

អ្នកត្រូវដុសលាងឯបទឹកដោះព្រមទាំងប្រដាប់ប្រដារប្រើប្រាស់ផ្សេងៗឲ្យបានហ្មត់ចត់ ជាមួយនឹង ទឹកសាប៊ូក្តៅឧណ្ហៗ ជាមុនសិន មុននឹងធ្វើការរម្ងាប់មេរោគ។

- លាងដៃឲ្យបានស្អាតហ្មត់ចត់។
- គ្រលែងឯប ក្បាលដោះព្រមទាំងប្រដាប់ប្រដារប្រើប្រាស់ ជាមួយនឹងទឹកត្រជាក់រួច លាងឲ្យបានស្អាតម្តងទៀត។
- សូមប្រើច្រាសសំរាប់ដុសឯប ដើម្បីលាងឯបព្រមទាំងក្បាលដោះខាងក្នុង ខាងក្រៅ ជាមួយនឹងទឹក សាប៊ូក្តៅឧណ្ហៗ។ សូមកុំភ្លេចដុសជុំវិញគន្លាក់ក្បាលឯបទឹកដោះ ពីព្រោះ ទឹកដោះជាធម្មតា ច្រើនកកផ្តុំនៅជុំវិញកន្លែងនេះ។ ចូរលាងគ្រលែងឯបជាមួយនឹងទឹកឲ្យបានស្អាតល្អ។

មានរបៀប៣យ៉ាងដើម្បីរម្ងាប់មេរោគ៖

- ការស្ងោរ
- ការរម្ងាប់មេរោគដោយប្រើល្បាយគីមីម៉្យាង
- ការស្ងោរចំហុយដើម្បីរម្ងាប់មេរោគ

## ស្ងោរ



- ត្រូវជ្រើសរើសយកឆ្នាំងមានគ្រប ហើយមានទំហំធំគ្រប់គ្រាន់ សំរាប់ដាក់ស្ងោរប្រដាប់ប្រដារទាំងអស់នោះ។



- ដាក់ប្រដាប់ប្រដារទាំងអស់នោះទៅក្នុងឆ្នាំង ហើយដាក់ទឹកឲ្យលិច របស់ទាំងអស់នោះ។




- ចូរដាំស្ងោរឲ្យពុះ ហើយទុកឲ្យពុះបាន៥នាទី។ ចូរបិទចង្ក្រាន ហើយកុំឲ្យទឹកក្នុងឆ្នាំងនោះពុះទាល់តែស្ងួត។




- លើកឆ្នាំងចេញពីចង្ក្រាន រួចទុកឲ្យត្រជាក់។ ចូរប្រើដៃស្អាតលើកយកប្រដាប់ប្រដារទាំងនោះចេញពីឆ្នាំង សម្រោះយកទឹកចេញ ហើយទើបរៀបរបស់ទាំងនោះទុកនៅទីកន្លែងស្អាតមួយ។

**ការរម្ងាប់មេរោគដោយប្រើល្បាយគីមីម៉្យាង (Cold sterilization using a chemical solution)**

ការរម្ងាប់មេរោគដោយប្រើល្បាយគីមី គឺងាយអនុវត្តជាង បើសិនលោកអ្នកមានវត្ថុជាច្រើនសំរាប់រម្ងាប់មេរោគ។ លោកអ្នកអាចប្រើល្បាយគីមីនេះ ដើម្បីធ្វើការរម្ងាប់នូវវត្ថុធាតុទាំងអស់ លើកលែងតែវត្ថុដែលធ្វើពីជាតិដែកចេញ។ លោកអ្នកត្រូវរម្ងាប់មេរោគនូវវត្ថុដែលធ្វើពីជាតិដែកដោយការស្ងោរ។



- ត្រូវលាយល្បាយរាវ (សូលូស្យុង)ទៅតាមរបៀបដែលគេណែនាំនៅលើឯប។ ថ្នាំរម្ងាប់មេរោគនេះ មានទ្រង់ទ្រាយជាគ្រាប់ថ្នាំ និងល្បាយរាវ (គឺ វាល់កំរិតចំនួនល្បាយគីមីរាវ ដាក់ចូលទៅក្នុងចំនួនទឹកតាមការណែនាំត្រឹមត្រូវ) ។



- ចូរជ្រមុជប្រដាប់ប្រដារប្រើប្រាស់ ឯបនិងក្បាលដោះឲ្យលិចស៊ប់ទៅក្នុងល្បាយទឹករម្ងាប់មេរោគ ដោយច្របាច់យកខ្យល់ចេញឲ្យអស់ពីក្បាលដោះ។



- ចូរទុករបស់ទាំងនោះក្នុងទឹកល្បាយរាវ ទៅតាមរយៈពេលកំណត់។



- ត្រូវយកដៃដែលស្អាតគ្មានរោគ ដកយកវត្ថុទាំងនោះចេញ។ រួចដាក់វត្ថុទាំងនោះនៅទីកន្លែងស្អាតល្អមួយដើម្បីសម្រោះទឹកចេញ។

សូមលាងសំអាតធុងសំរាប់ដាក់ល្បាយរាវរម្ងាប់មេរោគ និងផ្លាស់ល្បាយថ្មីរាល់ពេល២៤ម៉ោងម្តង។

## ការស្ងោរចំហុយដើម្បីរម្ងាប់មេរោគ

ការស្ងោរចំហុយរម្ងាប់មេរោគមាន២យ៉ាង គឺ៖

ការប្រើម៉ាស៊ីនមីក្រូវ៉េវ និងម៉ាស៊ីនប្រើអគ្គិសនី

- ដាក់វត្ថុទាំងនោះទៅក្នុងម៉ាស៊ីនរម្ងាប់មេរោគ ហើយត្រូវធ្វើយ៉ាងណាឲ្យជាតិទឹកទាំងឡាយ ដែលនៅក្នុងដប និងក្បាលដោះជាដើមអាចច្រោះស្ងួតបាន។
- ចូរប្រើម៉ាស៊ីនរម្ងាប់មេរោគទៅតាមការណែនាំនៃក្រុមហ៊ុនផលិតឧបករណ៍នោះ។
- ចូរប្រើដៃស្អាតគ្មានមេរោគដើម្បីឯកយកវត្ថុទាំងនោះចេញ។

លោកអ្នកគួរសំអាតឧបករណ៍រម្ងាប់មេរោគនេះឲ្យបានទៀងទាត់។